# សេចក្តីប្រកាសព័ត៌មានរួម

**សម្រាប់ការផ្សាយបន្ទាន់**

**ថ្ងៃព្រហស្បតិ៍ ទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០០៩**

## បេក្ខជនប្រកួតផ្តាច់ព្រ័ត្រចំនួន ២០ នាក់ដែលជាកម្មករកម្មការនីកាត់ដេរ នឹងប្រកួតប្រជែងនៅក្នុងពិធីបង្ហាញម៉ូតឆ្នាំ ២០០៩ ដែលមានឈ្មោះថា "ខ្ញុំមានតំលៃ"

បេក្ខជនផ្តាច់ព្រ័ត្រចំនួន ២០ នាក់ដែលជាកម្មករកម្មការនីកាត់ដេរ នឹងប្រកួតប្រជែងនៅក្នុងពិធីបង្ហាញម៉ូតសំលៀកបំពាក់ និងអាវយឺតមួយ ដែលជាកម្មវិធីបញ្ចប់នៃយុទ្ធនាការ "**ខ្ញុំមានតំលៃ**" សំរាប់ឆ្នាំ ២០០៩។ សំលៀកបំពាក់ចំនួន ១០ សម្រាប់ និងអាវយឺតចំនួន ១០ ដែលបានច្នៃម៉ូតដោយកម្មករកម្មការនីកាត់ដេរ នឹងត្រូវដាក់បង្ហាញនៅលើវេទិកា។ ម្ចាស់ជ័យលាភីសម្រាប់វិញ្ញាសានីមួយៗ នឹងត្រូវប្រកាសនៅ **ថ្ងៃអាទិត្យ ទី ២៩ ខែ វិច្ឆិកា វេលាម៉ោង ៤ រសៀល នៅឯសាលសន្និសីទចតុមុខ**។

យុទ្ធនាការ និង ការប្រកួត "**ខ្ញុំមានតំលៃ**" មានគោលបំណងលើកកម្ពស់តំលៃផ្ទាល់ខ្លួនរបស់កម្មករកម្មការនីកាត់ដេរ ដោយបង្កើនការយល់ដឹងពីការងារ សមត្ថភាព និងជំនាញរបស់ពួកគេ ហើយលើកទឹកចិត្តពួកគេឱ្យយល់ដឹងពីសក្តានុពលរបស់ខ្លួនគេផ្ទាល់។ ការប្រកួតប្រជែងនេះក៏មានគោលបំណងបង្ហាញឱ្យឃើញថា មានការងារល្អសមរម្យជាច្រើននៅក្នុងវិស័យកាត់ដេរ។ យុទ្ធនាការនេះក៏សង្ឃឹមថានឹងបង្កើនឱកាសការងារដល់កម្មករកម្មការនីកាត់ដេរ ខណៈពេលដែលពួកគេបានចូលរួមចំណែកកសាងកិត្តិនាមដ៏ល្អដល់វិស័យកាត់ដេរ ក៏ដូចជាចូលរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។ ម្យ៉ាងវិញទៀត យុទ្ធនាការនេះក៏ផ្តល់នូវរូបភាពវិជ្ជមានជាសកលដល់ឧស្សាហកម្មកាត់ដេរកម្ពុជា តាមរយៈការចូលរួមគាំទ្រពីអ្នកបញ្ជាទិញអន្តរជាតិនានា។

ពិធីនេះនឹងប្រព្រឹត្តទៅក្រោមអធិបតីភាព **លោកជំទាវ វេជ្ជបណ្ឌិត អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងមានការចូលរួមពីសំណាក់មន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាល និងអង្គការសហប្រជាជាតិ ដៃគូពាក់ព័ន្ធនានានៅក្នុងឧស្សាហកម្មកាត់ដេរកម្ពុជា និងកម្មករកម្មការនីកាត់ដេរ។

កម្មវិធីលើកទី ២ នៃយុទ្ធនាការ និងការប្រកួត "**ខ្ញុំមានតំលៃ**" ដែលប្រធានបទនៅក្នុងឆ្នាំនេះគឺ "**ផលិតនៅក្នុងប្រទេសកម្ពុជា**" ត្រូវបានចាប់ផ្តើមឡើងកាលពីពាក់កណ្តាលខែកក្កដា ហើយបានបើកទទួលពាក្យអស់រយៈពេល ២ ខែ។ ជាលទ្ធផល មានកម្មករកម្មការនីកាត់ដេរចំនួន ៤៦៥ នាក់ ដែលធ្វើការក្នុងរោងចក្រកាត់ដេរចំនួន ៣៩ បានបញ្ជូនម៉ូតសំលៀកបំពាក់ និងអាវយឺតជាង ១១០០ ម៉ូត មកចូលរួមធ្វើការប្រកួតប្រជែង។

ម៉ូតដែលត្រូវបានជ្រើសរើសក្នុងលំដាប់កំពូលចំនួន ១០ នៃវិញ្ញាសានីមួយៗ ត្រូវបានកាត់ចេញជាសំលៀកបំពាក់ និងអាវយឺត ហើយនឹងត្រូវសំរាច់ដោយគណៈកម្មការចំនួន ២ ក្រុមផ្សេងគ្នា ដែលមានសមាសភាពមកពីតំណាងរដ្ឋាភិបាល និងអ្នកឯកទេសនៅក្នុងវិស័យកាត់ដេរ និងផ្នែកច្នៃម៉ូតនៅកម្ពុជា។ ម្ចាស់ជ័យលាភីទាំងអស់ នឹងទទួលបានរង្វាន់។

រង្វាន់ទាំងនោះរួមមាន វគ្គបណ្តុះបណ្តាលធ្វើពុម្ពគំរូ ការធានារ៉ាប់រងសុខភាព សេវាថែទាំសុខភាពបន្តពូជ ម៉ាស៊ីនដេរ ទូរទស្សន៍ កង់ គណនីរបស់ក្រុមហ៊ុនវីង ព្រមជាមួយនិងទូរស័ព្ទចល័ត និងស៊ីមកាត សំលៀកបំពាក់ និងអាវយឺតដែលច្នៃដោយបេក្ខជនក្នុងវគ្គផ្តាច់ព្រ័ត្រ ក៏ដូចជាថវិកាផងដែរ។ លើសពីនេះទៅទៀត ម្ចាស់ជ័យលាភីលេខ ១ សម្រាប់វិញ្ញាសាច្នៃម៉ូតអាវយឺត នឹងចូលរួមច្នៃម៉ូតអាវយឺតថ្មីមួយដើម្បីចែកជូនដល់កម្មករកម្មការនីកាត់ដេរ។ រង្វាន់ទាំងនោះត្រូវបានឧបត្ថម្ភដោយក្រុមហ៊ុន H&M ក្រុមហ៊ុន Levi Strauss & Co. ក្រុមហ៊ុន Disney ក្រុមហ៊ុន GAP ក្រុមហ៊ុនវីង អង្គការម៉ារីស្ត្រូបអន្តរជាតិកម្ពុជា និងអ្នកឧបត្ថម្ភផ្សេងៗ ជាច្រើនទៀត។

**"ខ្ញុំមានតំលៃ"** គឺជាយុទ្ធនាការរួមគ្នាមួយក្រោមកិច្ចសហប្រតិបត្តិការរវាងក្រសួងកិច្ចការនារី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងពាណិជ្ជកម្ម គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជានៃអង្គការពលកម្មអន្តរជាតិ កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) សមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) មជ្ឈមណ្ឌលឧស្សាហកម្មដើម្បីបង្កើនលទ្ធភាពផលិតសំលៀកបំពាក់ (GIPC) សហជីព និងទស្សនាវដ្តីតំលៃនារី។

**កម្មវិធីបង្ហាញម៉ូតសំលៀកបំពាក់នេះ នឹងចាប់ផ្តើមនៅថ្ងៃអាទិត្យ ទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០៩ វេលាម៉ោង ៤ រសៀល នៅឯសាលសន្និសីទចតុមុខតាមបណ្តោយមហាវិថីស៊ីសុវត្ថិ។ អ្នកសារព័ត៌មានទាំងឡាយអាចចូលរួមក្នុងពិធីនេះដើម្បីយកព័ត៌មាន។**

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមក


លោក វ៉ុធ លីណូ
មន្ត្រីទំនាក់ទំនងព័ត៌មាន
គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា
នៃអង្គការពលកម្មអន្តរជាតិ
អ៊ីម៉ែល: g6bfc@ilo.org
ទូរស័ព្ទ: ០១២ ៧៥៦ ៧៦៥

កញ្ញា លីប៊ុន បុទុមរ័ត្ន
មន្ត្រីទំនាក់ទំនងព័ត៌មាន
គម្រោង TRADE
នៃក្រសួងពាណិជ្ជកម្ម និង UNDP
អ៊ីម៉ែល: Botumroath.Lebun@undp.org
ទូរស័ព្ទ : ០១២ ៨៨៥ ៧២៧